**United Nations Development Programme**

# PRESS RELEASE

Empowered lives.
Resilient nations.

# ការធ្វើទំនើបកម្មការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា

**ទីក្រុងភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨៖** ពិភពលោក កប់ខ្លួនក្នុងសំណល់រឹងកាន់តែលឿនទៅៗ។ ផ្លាស្ទិក ធ្វើឲ្យកកស្ទះផ្លូវទឹករបស់យើង។ ទីលានចាក់សម្រាម កាន់តែឆាប់ពេញជាងពេលណាៗទាំងអស់ នៅតាមប្រទេសនានានៅលើពិភពលោកទាំងមូល។ មិនតែប៉ុណ្ណោះ យើងថែមទាំងបានរកឃើញថាសំណល់ផ្លាស្ទិកជាប់លើផ្ទាំងទឹកកកនៅតំបន់អង់តាទិកថែមទៀតផង។

ចំណែកឯនៅប្រទេសកម្ពុជាវិញ ក្រសួងបរិស្ថានបានឲ្យដឹងថា ការចោលសំណល់រឹងនៅទីលានចាក់សម្រាមក្នុងទីក្រុងបានកើនឡើងយ៉ាងឆាប់រហ័សពី ៣១៨.០០០ តោន ក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០០៤ ដល់ ១,៥ លានតោន ក្នុងមួយឆ្នាំ នាឆ្នាំ២០១៧។ ស្ថានភាពនេះកាន់តែគួរឲ្យព្រួយបារម្ភនៅតាមទីក្រុងធំៗ ដូចជាទីក្រុងភ្នំពេញជាដើម ដែលទំហំនៃសម្រាមមានប្រមាណជាជាង ២.៣០០ តោន ជារៀងរាល់ថ្ងៃ។

នៅថ្ងៃនេះ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានប្រមូលផ្តុំអ្នកជំនាញគ្រប់គ្រងសំណល់រឹង ក្រុមហ៊ុនវិស័យឯកជន យុវជន អ្នកស្វែងរកមតិគាំទ្រ និងតំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតនូវសម្ព័ន្ធភាពមួយ ដើម្បីឆ្លើយតបចំពោះបញ្ហាដែលកាន់តែរីកធំឡើងនេះ។

លោក Nick Beresford នាយក UNDP ប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ក្នុងកិច្ចប្រជុំថ្នាក់ជាតិស្តីពីសេដ្ឋកិច្ចចក្រា (Circular Economy)៖ ការធ្វើទំនើបកម្មការគ្រប់គ្រងសំណល់រឹងនៅកម្ពុជា មានប្រសាសន៍ថា "របាយការណ៍កាលពីពេលថ្មីៗ ដែលបានលើកឡើងថា សំណល់ផ្លាស្ទិកបានចូលទៅក្នុងទឹកដែលយើងគ្រប់គ្នាបរិភោគ គឺជារឿងគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំង។ កិច្ចប្រជុំនៅថ្ងៃនេះ គឺជាកិច្ចប្រជុំទាន់ពេលវេលា និងផ្តល់នូវក្តីសង្ឃឹម ប៉ុន្តែខ្ញុំសូមអំពាវនាវឲ្យមនុស្សទាំងអស់ចូលរួមចាត់វិធានការជាមួយយើង ក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយសំណល់ និងផ្លាស្ទិក។ នេះគឺជាកិច្ចការដែលសំខាន់បំផុតដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងជួយសង្គ្រោះភពផែនដីរបស់យើង។"

យើងអាចមានដំណោះស្រាយមួយចំពោះបញ្ហាសំណល់រឹងរបស់យើង។ នៅពេលដែលយើងពិនិត្យមើលកាន់តែច្បាស់ យើងឃើញថា សំណល់ជាង ៩០% ក្នុងចំណោមសំណល់ទាំងអស់ មានសម្ភារៈដែលអាចយកទៅកែច្នៃប្រើឡើងវិញបាន។ ហើយបរិមាណសម្ភារៈដែលអាចយកទៅកែច្នៃឡើងវិញនេះ ក៏បន្តមានការកើនឡើងជារៀងរាល់ឆ្នាំផងដែរ។

មាគ៌ាមួយសម្រាប់ការអភិវឌ្ឍនៅកម្ពុជា គឺប្រើប្រាស់អភិក្រមសេដ្ឋកិច្ចចក្រា។ ទស្សនទានដែលទើបតែលេចចេញជារូប

និរន្តរភាព។ សេដ្ឋកិច្ចចក្រា មានគោលបំណងកាត់បន្ថយកម្រិតឧស្ម័នមេតាន ជាឧស្ម័នមួយក្នុងចំណោមឧស្ម័នផ្ទះកញ្ចក់សំខាន់ៗដែលបំភាយចេញពីវិស័យសំណល់។

លោកស្រីបណ្ឌិត Moeko Saito Jensen ប្រធានផ្នែកគោលនយោបាយ និងជាទីប្រឹក្សាផ្នែកបរិស្ថានរបស់ UNDP បានពន្យល់ថា "លើសពីការអនុវត្តនាពេលបច្ចុប្បន្ន ដែលគ្រាន់តែផលិតយកទៅប្រើប្រាស់រួចបោះបង់ចោល សេដ្ឋកិច្ចចក្រា មានគោលបំណងជម្រុញដល់កំណើនសេដ្ឋកិច្ច ដោយផ្ដោតលើអត្ថប្រយោជន៍ជាវិជ្ជមានសម្រាប់សង្គមទាំងមូល"។

សេដ្ឋកិច្ចចក្រា តម្រូវឱ្យមានការកាត់បន្ថយសកម្មភាពសេដ្ឋកិច្ចជាបណ្ដើរៗ ពីការប្រើប្រាស់ធនធានដែលមានកំណត់ និងធ្វើឲ្យគ្មានសំណល់ក្នុងប្រព័ន្ធសេដ្ឋកិច្ច។ ជាមួយនឹងការធ្វើអន្តរកាលទៅរកប្រភពថាមពលកកើតឡើងវិញ គំរូសេដ្ឋកិច្ចចក្រានេះ នឹងជួយកសាងនូវមូលដ្ឋានសេដ្ឋកិច្ច ធនធានធម្មជាតិ និងធនធានសង្គម។ គំរូសេដ្ឋកិច្ចចក្រានេះ ផ្អែកតាមគោលការណ៍ចំនួនបី៖

- កាត់បន្ថយ (reduce)៖ រៀបចំដើម្បីកាត់បន្ថយសំណល់ និងការបំពុល
- ការប្រើប្រាស់ឡើងវិញ (reuse)៖ រក្សាផលិតផល និងវត្ថុធាតុដើមដែលកំពុងប្រើប្រាស់ និង
- ការកែច្នៃឡើងវិញ (recycle)៖ បង្កើតប្រព័ន្ធធម្មជាតិឡើងវិញ

ក្នុងរយៈពេលប៉ុន្មានសប្ដាហ៍កន្លងទៅនេះ វេទិកាសេដ្ឋកិច្ចចក្រាពិភពលោកទីពីរ ត្រូវបានរៀបចំឡើងក្នុងប្រទេសជប៉ុន។ វេទិកានេះមានអ្នកចូលរួមជាង ១.០០០ នាក់ មកពីប្រទេសចំនួន ៨០ ក្នុងនោះមានប្រតិភូជាន់ខ្ពស់ពីរាជរដ្ឋាភិបាលកម្ពុជាផងដែរ។

ឯកឧត្តម ង វុទ្ធី អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព មានប្រសាសន៍ថា "រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈយ៉ាងមុតមាំក្នុងកិច្ចខិតខំប្រឹងប្រែងជារួមរបស់យើង ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងឆ្នាំ ២០៣០។ យើងសូមស្វាគមន៍វិធីសាស្ត្រថ្មីបែបនវានុវត្តន៍ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់ ហើយយើងត្រៀមខ្លួនជាស្រេចដើម្បីសហការជាមួយនឹងដៃគូថ្មីៗរបស់យើង។"

កិច្ចប្រជុំថ្នាក់ជាតិស្ដីពីសេដ្ឋកិច្ចចក្រានេះ មានគោលបំណងកំណត់ពីគោលនយោបាយជាអាទិភាព សកម្មភាពធុរកិច្ច សកម្មភាពសាធារណៈនានា ដើម្បីលើកកម្ពស់ដំណោះស្រាយសម្រាប់គ្រប់គ្រងសំណល់នៅកម្ពុជា។

### ### ###

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងលោក **អ៊ឹម សំរួល** មន្ត្រីផ្នែកទំនាក់ទំនងរបស់ UNDP តាមរយៈ samruol.im@undp.org។